## តើអ្នកគួររាយការណ៍ដោយរបៀបណា ប្រសិនបើអ្នកសង្ស័យថាកុមារអាចមានគ្រោះថ្នាក់តាមអនឡាញ?

សម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងសកម្មភាពសង្ស័យតាមអនឡាញអាចត្រូវបានរាយការណ៍ទៅកាន់លេខទូរស័ព្ទជំនួយបន្ទាន់របស់អង្គការសកម្មភាពដើម្បីកុមារ (APLE) តាមរយៈលេខ៖

**០៩២ ៣១១ ៥១១**




អ្នកក៏អាចរាយការណ៍តាមបណ្ដាញរាយការណ៍ពិសេសតាមរយៈគេហទំព័រខាងក្រោម៖
**www.internethotlinecambodia.org**
ផងដែរ ដោយគ្រាន់តែចុចប៊ូតុង "រាយការណ៍ករណី" ឬ **"Report Abuse"** រួចបំពេញនូវទម្រង់តាមប្រព័ន្ធអនឡាញជាការស្រេច។

"រាយការណ៍ករណី" ឬ "Report Abuse"

ប្រសិនបើកុមារស្ថិតក្នុងគ្រោះថ្នាក់បន្ទាន់ណាមួយ សូមរាយការណ៍ទៅកាន់នគរបាលដែលនៅជិតលោកអ្នកបំផុត ឬទូរស័ព្ទទៅកាន់លេខទូរស័ព្ទជំនួយបន្ទាន់របស់នគរបាលជាតិតាមរយៈលេខ៖ **1288**

ការរាយការណ៍របស់អ្នកអាចធ្វើឡើងដោយអនាមិក។



APLE 20 YEAR

# ការការពារកុមារ ពីហានិភ័យតាមអនឡាញ

## ព័ត៌មានសម្រាប់ឪពុកម្ដាយ

ផលិតដោយ៖
APLE 20 YEAR

ឧបត្ថម្ភដោយ៖
CHILDHOOD
WORLD CHILDHOOD FOUNDATION
FOUNDED BY H.M. QUEEN SILVIA OF SWEDEN



## ក្នុងនាមជាឪពុកម្ដាយ ការរក្សាកូនៗឱ្យមានសុវត្ថិភាពគឺជាកិច្ចការអាទិភាពមួយ។ ប៉ុន្តែតើអ្នកដឹងទេថា នៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត ពួកគេក៏ត្រូវការការការពារដែរ?




### ហានិភ័យពាក់ព័ន្ធនឹងមាតិកា (Content Risks)

កុមារអាចមើលឃើញនូវមាតិកាដែលពួកគេមិនចង់ឃើញ ឬមាតិកាដែលមានលក្ខណៈមិនសមរម្យ។ វាអាចជាប្រភេទវីដេអូ រូបភាព អត្ថបទ សារសម្លេងតាមអនឡាញ ដែលមានលក្ខណៈផ្លូវភេទ អាសអាភាស ឬមានលក្ខណៈហិង្សាជាដើម។



### ហានិភ័យទំនាក់ទំនង (Contact Risks)

មនុស្សមួយចំនួនប្រើប្រាស់អ៊ីនធឺណិត ជាមធ្យោបាយក្នុងការទាក់ទងកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ កុមារអាចចូលរួមដោយមិនបានដឹងខ្លួនក្នុងការប្រាស្រ័យទាក់ទងប្រកបដោយគ្រោះថ្នាក់ជាមួយអ្នកដទៃតាមអនឡាញ ហើយពួកគេអាចត្រូវបានគេបោកបញ្ឆោតឱ្យមានទំនាក់ទំនងបែបផ្លូវភេទ។

ទំនាក់ទំនងបែបផ្លូវភេទពេលខ្លះកើតឡើងតែតាមអនឡាញតែប៉ុណ្ណោះ ដោយមិនមានការជួបផ្ទាល់ជាមួយកុមារឡើយ។ តាមអនឡាញជនល្មើសអាចបង្ខំ ឬរៀបចំឱ្យកុមារធ្វើសកម្មភាពផ្លូវភេទនៅមុខកាមេរ៉ា ឬជនល្មើសអាចផលិតរូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ។



### ហានិភ័យដែលកើតពីការប្រព្រឹត្តដោយផ្ទាល់ (Conduct Risks)

ពេលខ្លះកុមារខ្លួនឯងអាចមានឥរិយាបទចូលរួមចំណែក បង្កើតនូវមាតិកាបែបហានិភ័យ ឬចូលរួមក្នុងទំនាក់ទំនង បែបហានិភ័យតាមអនឡាញដោយខ្លួនឯង។ សកម្មភាពទាំងនោះអាចជាការផលិត បង្ហោះ ឬចែកចាយរូបភាពអាក្រាត ឬរូបភាពបែបផ្លូវភេទខ្លួនឯង និងអ្នកដទៃ ដោយមិនបានយល់ដឹងពីផលវិបាកដែលនឹងកើតមានឡើង។

## ខណៈពេលកំពុងប្រើប្រាស់អ៊ីនធឺណិត កូនរបស់អ្នកអាចប្រឈមទៅនឹងហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទ

កុមារត្រូវការការណែនាំរបស់ឪពុកម្ដាយ ដើម្បីអាចដឹងពីឥរិយាបទតាមអនឡាញ ដែលមានសុវត្ថិភាព ហើយអាចបែងចែករវាងទំនាក់ទំនងដែលមានលក្ខណៈសមរម្យ និងមិនសមរម្យជាមួយអ្នកដទៃនៅលើអ៊ីនធឺណិត។



## ការផលិតនិងចែកចាយសម្ភារៈរំលោភបំពានផ្លូវភេទកុមារគឺជាបទល្មើសយ៉ាងធ្ងន់ធ្ងរ!

### អ្វីដែលឪពុកម្ដាយអាចធ្វើបាន?

សូមពិភាក្សាជាមួយកូនរបស់អ្នកពីហានិភ័យដែលអាចកើតមានឡើងតាមអនឡាញ ក៏ដូចជាប្រាប់ពួកគេពីរបៀបរក្សាសុវត្ថិភាព។ ប្រសិនបើកូនរបស់អ្នកធ្លាប់បានជួបប្រទះ ឬរងផលប៉ះពាល់ដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ វាពិតជា សំខាន់ណាស់ដែលឪពុកម្ដាយមិនត្រូវស្ដីបន្ទោសពួកគេនោះឡើយ ព្រោះវាមិនមែនជាកំហុសរបស់ពួកគេនោះទេ។



ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារអាចបណ្ដាលឱ្យមានការប៉ះទង្គិច និងមានផលប៉ះពាល់ដល់សុខុមាលភាពផ្លូវចិត្តរបស់កុមារ ដូចនេះអ្វីដែលពួកគេត្រូវការគឺការគាំទ្ររបស់អ្នកជាឪពុកម្ដាយ ដើម្បីឱ្យពួកគេមានភាពប្រសើរឡើងវិញ ជាងនេះទៅទៀតគឺការរាយការណ៍អំពីករណីនៃការកេងប្រវ័ញ្ចនោះ។

តាមរយៈការរាយការណ៍ពីសម្ភារៈរំលោភបំពានផ្លូវភេទកុមារតាមអនឡាញ នោះអ្នកកំពុងតែបានជួយកុមារឱ្យមានទំនុកចិត្តឡើងវិញ ហើយរស់នៅក្នុងជីវិតដែលមានភាពល្អប្រសើរ។



ការរាយការណ៍របស់អ្នក ក៏អាចជួយឱ្យមានការដកហូតនូវសម្ភារៈរំលោភបំពានទាំងនោះចេញពីអ៊ីនធឺណិត និងជួយនាំជនល្មើសទៅផ្ដន្ទាទោសតាមច្បាប់។